**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ៖ សហមេធាវីការពារក្តី អៀង សារី និង មាស មុត

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jun-2016, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# សំណើបន្ទាន់របស់សហមេធាវីរបស់លោក អៀង សារី និង លោក មាស មុត សុំអនុញ្ញាតដាក់សារណាស្តីពីសក្ខីកម្មរបស់សាក្សីជំនាញ MICHAEL VICKERY

---

**ដាក់ដោយ៖**

**សហមេធាវីលោក អៀង សារី និង លោក មាស មុត៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន៖**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ៖**

ចៅក្រម និល ណុន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូរ ឧត្តរា

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ក្រុមមេធាវីការពារក្តីទាំងអស់ក្នុងរឿងក្តី ០០២**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

# សំណើបន្ទាន់របស់សហមេធាវីរបស់លោក អៀង សារី និង លោក មាស មុត សុំអនុញ្ញាតដាក់សារណាស្តីពីសក្ខីកម្មរបស់សាក្សីជំនាញ MICHAEL VICKERY

លោក អាង ឧត្តម និង លោក Michael G. Karnavas ដែលជាសហមេធាវីរបស់លោក អៀង សារី ក្នុងរឿងក្តី ០០២ និង លោក មាស មុត ក្នុងរឿងក្តី ០០៣ តាមរយៈនេះ ស្នើសុំការអនុញ្ញាតដាក់សារណាទាក់ទងនឹងសក្ខីកម្មនៃសាក្សីជំនាញ Michael Vickery ("សំណើសុំការអនុញ្ញាត")។ សំណើសុំការអនុញ្ញាតនេះត្រូវបានធ្វើឡើងជាចាំបាច់ ដើម្បីធានាឲ្យមានការបន្តរក្សាការសម្ងាត់នៃការប្រាស្រ័យទាក់ទង និង ការការពារបុព្វសិទ្ធិមេធាវី-កូនក្តី ដែលមានរវាងលោក Vickery សហមេធាវី និង លោក អៀង សារី នៅក្នុងរឿងក្តី ០០២ និង រវាងលោក Vickery សហមេធាវី និង លោក មាស មុត នៅក្នុងរឿងក្តី ០០៣។ លោក Vickery បានបំពេញការងារជាមួយមេធាវីការពារក្តី អៀង សារី ចាប់ពីខែមករា ឆ្នាំ ២០០៨ រហូតដល់ខែមីនា ឆ្នាំ ២០១៣ ដែលមានរយៈពេលប្រមាណ ១៥២០ ម៉ោង និង ជាមួយមេធាវីការពារក្តី មាស មុត នៅខែធ្នូ ឆ្នាំ ២០១៥ ដែលមានរយៈពេលសរុបចំនួន ១២០ ម៉ោង។ ដោយហេតុថាលោក Vickery ជាប់ពាក់ព័ន្ធជិតស្និទ្ធជាមួយក្រុមមេធាវីការពារក្តី សហមេធាវីស្នើសុំការអនុញ្ញាតដាក់សារណាដែលលើកទឡ្ហីករណ៍ឲ្យ៖ **ក.** ដាក់កម្រិតតឹងតែងលើសក្ខីកម្មរបស់លោក Vickery ឲ្យនៅត្រឹមតែព័ត៌មានដែលមានក្នុងសៀវភៅ និង ឯកសារបោះពុម្ពផ្សាយផ្សេងទៀតរបស់គាត់ **ខ.** មិនអនុញ្ញាតឲ្យគាត់ផ្តល់សក្ខីកម្មទាក់ទងនឹងព័ត៌មានណាមួយ ដែលគាត់បានដឹងក្នុងអំឡុងពេលបំពេញការងារជាមួយមេធាវីការពារក្តី អៀង សារី និង មេធាវីការពារក្តី មាស មុត និង **គ.** សហមេធាវីត្រូវមានវត្តមាននៅក្នុងសាលសវនាការក្នុងអំឡុងពេលដែលលោក Vickery ផ្តល់សក្ខីកម្ម និង ត្រូវបានអនុញ្ញាតឲ្យធ្វើអន្តរាគមន៍ ឬ ជំទាស់ ប្រសិនបើសក្ខីកម្មរបស់គាត់ចាប់ផ្តើមពិភាក្សាពីការសម្ងាត់ណាមួយ ដែលទាក់ទងនឹងរឿងក្តីរបស់លោក អៀង សារី ឬ លោក មាស មុត។

## I. សាវតារ

### *រឿងក្តី ០០២*

១. នៅថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៧ លោក អាង ឧត្តម ត្រូវបានតែងតាំងជាសហមេធាវីជាតិការពារក្តីលោក អៀង សារី[1]។ នៅខែធ្នូ ឆ្នាំ ២០០៧ លោក Karnavas ត្រូវបានតែងតាំងជាសហមេធាវីអន្តរជាតិការពារក្តីលោក អៀង សារី[2]។

[1] *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក. ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៧ *អាចរកបាននៅ* http://www.eccc.gov.kh/sites/default/files/media/Ieng_sary_and_Ieng_Thirith_select_lawyers.pdf។

២. នៅថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៨ លោក Vickery ត្រូវបានជួលឲ្យបំពេញការងារជាទីប្រឹក្សាជំនាញសម្រាប់មេធាវីការពារក្តី អៀង សារី។ គាត់បានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដើម្បីពិនិត្យស្វែងយល់។ គាត់បានវិភាគឯកសារនេះ និង ចំណាយពេលវេលាជាច្រើនម៉ោងជាមួយលោក អៀង សារី និង មេធាវីការពារក្តី អៀង សារី ដើម្បីពិភាក្សាពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ។ នៅពេលដែលចេញដីកាដំណោះស្រាយ លោក Vickery លោក អៀង សារី និង មេធាវីការពារក្តី អៀង សារី បានជួបគ្នាជាញឹកញាប់ដើម្បីពិភាក្សា *ក្នុងចំណោមនោះ* អំពីការចោទប្រកាន់ប្រឆាំងនឹងលោក អៀង សារី អង្គហេតុប្រវត្តិសាស្ត្រដែលទាក់ទងនឹងរឿងក្តី សាក្សីជាសក្ខានុភូតរបស់មេធាវីការពារក្តី និង ទ្រឹស្តីជាសក្ខានុភូតនៃរឿងក្តី ព្រមទាំងយុទ្ធសាស្ត្រសម្រាប់ការចូលរួម រួមទាំងផ្នែកត្រួតពិនិត្យសាក្សីផងដែរ។ ដោយហេតុថាគាត់បានបំពេញការងារជាមួយមេធាវីការពារក្តី អៀង សារី នៅមុនពេលបំបែករឿងក្តី ០០២[3] កិច្ចពិភាក្សាទាំងនេះមានបញ្ចូលផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការបោសសម្អាតដែលរងការចោទប្រកាន់ផងដែរ។

៣. នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០១១ កិច្ចដំណើរការនីតិវិធីជំនុំជម្រះប្រឆាំងនឹងលោក នួន ជា លោក អៀង សារី អ្នកស្រី អៀង ធីរិទ្ធ និង លោក ខៀវ សំផន បានចាប់ផ្តើមក្នុងរឿងក្តី ០០២[4]។ លោក Vickery បានបន្តបំពេញការងារជាមួយមេធាវីការពារក្តី អៀង សារី ក្នុងនាមជាទីប្រឹក្សាជំនាញដែលពិគ្រោះយោបល់ជាប្រចាំជាមួយលោក អៀង សារី និង មេធាវីការពារក្តី អៀង សារី អំពីផ្នែកទាំងអស់នៃដីកាដំណោះស្រាយ យុទ្ធសាស្ត្រជំនុំជម្រះក្តី និង ការការពារក្តី និង សាក្សី។

៤. នៅថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៣ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក អៀង សារី ត្រូវបានបញ្ចប់ដោយសារតែគាត់បានទទួលមរណភាព[5]។

---

[2] *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក. ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៧ *អាចរកបាននៅ* http://www.eccc.gov.kh/sites/default/files/media/IS-14-DSS-Press_Release_Karnavas_Assignment_ENG.pdf។

[3] រឿងក្តី ០០២ ត្រូវបានបំបែកនៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១១។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១១ ឯកសារ E124។

[4] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ សវនាការបឋម ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E1/4.1។

[5] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៣ ឯកសារ E270/1។

៥. នៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឆ្លើយតបទៅនឹងសំណើសុំតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. របស់មេធាវីការពារក្ដីនួន ជា ការិយាល័យសហព្រះរាជអាជ្ញាបានកត់សម្គាល់ថា លោក Vickery គ្រោងនឹងត្រូវផ្ដល់ សក្ខីកម្មក្នុងរឿងក្ដី 00២/0២ លើប្រធានបទការបោសសម្អាត[6]។

***រឿងក្ដី ០០៣***

៦. នៅថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ កិច្ចស៊ើបសួររឿងក្ដី ០០៣ ត្រូវបានផ្ដួចផ្ដើម ដោយផ្អែកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទងទៅនឹងកងទ័ពបដិវត្តន៍កម្ពុជា[7]។

៧. នៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១២ អង្គភាពគាំពារការការពារក្ដីបានតែងតាំងលោក អាង ឧត្ដម និង លោក Karnavas ជាសហមេធាវីការពារក្ដីលោក មាស មុត[8]។

៨. នៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៥ លោក Vickery ត្រូវបានជួលឱ្យបំពេញការងារជាទីប្រឹក្សាជំនាញសម្រាប់មេធាវីការពារក្ដី មាស មុត ដើម្បីពិនិត្យស្វែងយល់ វិភាគ និង ផ្ដល់មតិយោបល់លើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងរឿងក្ដី ០០៣ និង ឯកសារគាំទ្រដីកានេះ។ កិច្ចសន្យាការងាររបស់គាត់មានរយៈពេល ១២០ ម៉ោង។ ការបន្តចូលរួមពាក់ព័ន្ធរបស់គាត់ក្នុងរឿងក្ដី ០០៣ ត្រូវបានរំពឹងទុកនៅក្នុងឆ្នាំ ២០១៦ ជាពិសេសនៅក្រោយពេលបញ្ចប់ការស៊ើបអង្កេតរបស់តុលាការ ប្រសិនបើមានការចេញដីកាដំណោះស្រាយ ហើយសំណុំរឿងនេះត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងនោះ។

---

[6] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទិននឹង Alexander Hinton (2-TCE-88) ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ E405/1។

[7] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងកងទ័ពបដិវត្តន៍កម្ពុជា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។

[8] ការកំណត់លើការអះអាងនៃភាពក្រីក្ររបស់លោក និង សេចក្ដីសម្រេចលើសំណើសុំបើកប្រាក់កម្រៃសហមេធាវីក្រោមគ្រោងការជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក. ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៣ ឯកសារ D56/11 កថាខណ្ឌ ៤។ ដំបូងឡើយ លោក អាង ឧត្ដម និង លោក Karnavas ត្រូវបានតែងតាំងក្នុងលក្ខខណ្ឌ *មិនគិតប្រាក់កម្រៃ* (pro bono) ដោយយល់ឃើញថា សហមេធាវីនឹងទទួលបានប្រាក់បៀវត្សរ៍ជាប្រតិសកម្មក្រោមគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក. ប្រសិនបើលោក មាស មុត ត្រូវបានកំណត់ថាជាជនក្រីក្រនោះ។

## II. ភាពអាចទទួលយកបាននៃសំណើសុំការអនុញ្ញាត

៩. សហមេធាវីស្នើសុំការអនុញ្ញាតដាក់សារណាទាក់ទងនឹងសក្ខីកម្មរបស់លោក Vickery ក្នុងនាមជាសាក្សីជំនាញក្នុងរឿងក្តី ០០២/០២។ សំណើសុំការអនុញ្ញាតនេះគឺស្រដៀងគ្នានឹងសំណើសុំធ្វើអន្តរាគមន៍ក្នុងរឿងក្តី ០០២/០២។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា កិច្ចអន្តរាគមន៍របស់ភាគីមួយក្នុងរឿងក្តីរបស់ភាគីមួយទៀតអាចត្រូវបានអនុញ្ញាត “ទៅតាមករណីជាក់ស្តែងនីមួយៗ នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ”[9] នៅពេលដែលកិច្ចអន្តរាគមន៍នោះគឺជា “ផលប្រយោជន៍ស្របច្បាប់” របស់ភាគីដែលស្នើសុំនោះ ហើយបើត្រូវបានបដិសេធវិញនោះ អាចបង្កផលប៉ះពាល់ដល់ភាគីនោះ”[10]។ លោក Vickery ធ្លាប់ជាទីប្រឹក្សាជំនាញសម្រាប់ទាំងមេធាវីការពារក្តី អៀង សារី ទាំងមេធាវីការពារក្តី មាស មុត។ ហេតុនេះក្នុងរឿងក្តី ០០២ គាត់បានជួបជាមួយលោក អៀង សារី សហមេធាវី និង សមាជិកក្រុមមេធាវីការពារក្តី ជាច្រើនលើកច្រើនសារ ដើម្បីពិភាក្សាពីអង្គហេតុ សាក្សី និង យុទ្ធសាស្ត្រទាក់ទងនឹងបទចោទប្រកាន់ និង រឿងក្តី។ ក្នុងរឿងក្តី ០០៣ គាត់បានផ្តល់ឲ្យសហមេធាវី និង សមាជិកក្រុមមេធាវីការពារក្តី នូវការវិភាគលើការចោទប្រកាន់តាមអង្គហេតុ ដែលមានក្នុងរឿងក្តី។

១០. វាជាប្រយោជន៍យុត្តិធម៌ក្នុងការអនុញ្ញាតឲ្យលោក អាង ឧត្តម និង លោក Karnavas ដែលជាសហមេធាវីរបស់លោក អៀង សារី និង លោក មាស មុត ដាក់សារណាស្តីពីការកំណត់ព្រំដែនលើសក្ខីកម្មរបស់លោក Vickery។ ដោយសារតែលោក Vickery ធ្លាប់ធ្វើការជាមួយលោក អៀង សារី (ដូចជា ការពិគ្រោះយោបល់ជាមួយលោក អៀង សារី និង សមាជិកក្រុមមេធាវីការពារក្តីទាក់ទងនឹងការចោទប្រកាន់ពីការបោសសម្អាតក្នុងដីកាដំណោះស្រាយ) និង ក្នុងរឿងក្តី ០០៣ មានហានិភ័យពិតប្រាកដដែលថា សក្ខីកម្មរបស់គាត់អាចរំលោភបំពានលើការសម្ងាត់ក្នុងរឿងក្តីរបស់លោក អៀង សារី និង លោក មាស មុត។ សហមេធាវីស្នើសុំឲ្យលោក Vickery មិនទទួលបានការអនុញ្ញាតឲ្យផ្តល់សក្ខីកម្មទាក់ទងនឹងព័ត៌មានណាមួយ ដែលគាត់បានដឹងតាមរយៈការពិគ្រោះយោបល់របស់គាត់ជាមួយមេធាវីការពារក្តី អៀង សារី និង មេធាវីការពារក្តី មាស មុត ឬ តាម

---

[9] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬ សុំដាក់សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្តី* នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ F20/1 កថាខណ្ឌ ១២។

[10] *ដូចខាងលើ* កថាខណ្ឌ ១១។

រយៈកិច្ចការស្រាវជ្រាវឯករាជ្យណាមួយ ដែលក្រុមមេធាវីការពារក្តីទាំងនេះបានចាត់តាំងឱ្យលោកបំពេញ។ សហមេធាវីស្វែងរកការការពារផលប្រយោជន៍របស់លោក អៀង សារី និងលោក មាស មុត និង ធានាថា គ្មានការរំលោភបំពានលើការសម្ងាត់ក្នុងរឿងក្តីរបស់លោក អៀង សារី និង លោក មាស មុត ក្នុងអំឡុងពេលដែលលោក Vickery ផ្តល់សក្ខីកម្ម។

១១. អង្គជំនុំជម្រះសាលាដំបូង ត្រូវអនុញ្ញាតឱ្យសហមេធាវីធ្វើអន្តរាគមន៍ តាមរយៈការដាក់សារណាជាលាយលក្ខណ៍អក្សរក្នុងរឿងក្តី ០០២/០២ និង មានវត្តមានក្នុងសាលសវនាការក្នុងអំឡុងពេលដែលលោក Vickery ផ្តល់សក្ខីកម្ម។ សហមេធាវីត្រូវតែមានវត្តមានដើម្បីធ្វើការជំទាស់ ប្រសិនបើសក្ខីកម្មរបស់លោក Vickery ដើរទៅរកបញ្ហាសម្ងាត់។ ដូចដែលនិយាយលម្អិតជាងនេះ *ខាងក្រោម* ប្រសិនបើសំណើសុំការអនុញ្ញាតនេះត្រូវបានច្រានចោលនោះ ផលប្រយោជន៍របស់លោក អៀង សារី និង លោក មាស មុត នឹងទទួលរងព្យសនកម្ម។ គ្មានច្បាប់កម្ពុជា ឬ ច្បាប់ អ.វ.ត.ក. ឬ វិធាននីតិវិធីណាមួយហាមឃាត់មិនឱ្យមានកិច្ចអន្តរាគមន៍បែបនេះឡើយ។

## III. ឧត្ថម្ភករណ៍គាំទ្រកិច្ចអន្តរាគមន៍ក្នុងរឿងក្តី ០០២/០២

១២. វិធាន ២២[11] និង មាត្រា ៧ នៃក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា[12] តម្រូវឱ្យសហមេធាវីបំពេញកិច្ចដោយយកចិត្តទុកដាក់ខ្ពស់ និង ស្មោះត្រង់ និង រក្សាការសម្ងាត់ក្នុង

---

[11] វិធាន ២២ (៣)-(៤) នៃវិធានផ្ទៃក្នុង៖ "រាល់ការទំនាក់ទំនងទាំងអស់រវាងមេធាវី និង កូនក្តីរបស់ពួកគេ ត្រូវរក្សាការសម្ងាត់ ហើយមិនត្រូវមានការលួចស្តាប់ ឬ ថត ឬ ថតចម្លងដោយជនផ្សេងឡើយ...។ នៅក្នុងការបំពេញការងាររបស់ខ្លួន មេធាវីត្រូវគោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និង បទបញ្ជារដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា និង បទដ្ឋាន និង ក្រមសីលធម៌វិជ្ជាជីវៈដែលបានទទួលស្គាល់។ ពួកគេមានកាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និង ដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាព និង ត្រឹមត្រូវ"។ *សូមមើលផងដែរ* វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[12] មាត្រា ៧ នៃក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា៖ "មេធាវីត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួនដាច់ខាតនូវការសម្ងាត់វិជ្ជាជីវៈ។ ការសម្ងាត់នេះមិនត្រូវអាចឱ្យជនណាម្នាក់ស្រង់យកបានឡើយ ទោះបីជាអតិថិជនក៏ដោយ"។ ការរំលោភបំពានមាត្រានេះ គឺជាបទល្មើសព្រហ្មទណ្ឌតាមមាត្រា ៧៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី (ឆ្នាំ ១៩៩៥) និង មាត្រា ៣១៤ នៃក្រមព្រហ្មទណ្ឌ (ឆ្នាំ ២០០០)។ បទប្បញ្ញត្តិទាំងនេះស្រដៀងគ្នានឹងវិធានបារាំងស្តីពីការសម្ងាត់រវាងមេធាវី និង កូនក្តី។ មាត្រា ២.១ នៃ *វិធានផ្ទៃក្នុងជាតិនៃវិជ្ជាជីវៈមេធាវី* (Reglement Interieur national (RIN) de la Profession d'Avocat) ចែងថា៖ "L'avocat est le confident nécessaire du client. Le secret professionnel de l'avocat est d'ordre public. Il est général, absolu et illimité dans le temps. Sous réserve des strictes exigences de sa propre défense devant toute juridiction et des cas de déclaration ou de révélation prévues ou autorisées par la loi, l'avocat ne commet, en toute matière, aucune divulgation contrevenant au secret professionnel."។ ការបកប្រែក្រៅផ្លូវការ៖ "មេធាវីគឺជាការសម្ងាត់ចាំបាច់នៃកូនក្តី។

រឿងក្តីរបស់លោក អៀង សារី និង លោក មាស មុត[13]។ បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី បំភ្លឺថា ករណីយកិច្ចរក្សាការសម្ងាត់គ្របដណ្តប់លើសមាជិកទាំងអស់នៃក្រុមមេធាវីការពារក្តី[14]។ វិសាលភាពនៃករណីយកិច្ចនេះឆ្លុះបញ្ចាំងនូវវិធាននានារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ[15] និង សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី[16] ដែលតម្រូវឲ្យ

---

ការសម្ងាត់វិជ្ជាជីវៈនៃមេធាវី គឺជាបទបញ្ជាសាធារណៈ។ វាមានលក្ខណៈទូទៅ ដាច់ខាត និង គ្មានព្រំដែនកំណត់។ លុះត្រាតែមានតម្រូវការមែនទែនក្នុងការការពារក្តីរបស់ខ្លួននៅចំពោះមុខតុលាការទាំងអស់ និង ក្នុងករណីដែលការប្រកាស ឬ ការទម្លាយព័ត៌មានសម្ងាត់មានចែង ឬ អនុញ្ញាតដោយច្បាប់ ក្នុងគ្រប់រូបភាពទាំងអស់ មេធាវីមិនត្រូវទម្លាយព័ត៌មានសម្ងាត់ ដែលរំលោភបំពានលើការសម្ងាត់វិជ្ជាជីវៈឡើយ"។ ការរំលោភបំពានលើមាត្រានេះនឹងត្រូវទទួលទណ្ឌកម្មតាមមាត្រា ២២៦-១៣ នៃក្រមព្រហ្មទណ្ឌបារាំង។

[13] *សូមមើល* វិធាន ១.៦(ក) នៃក្រមសីលធម៌វិជ្ជាជីវៈអាឡាស្កា (ឆ្នាំ ២០១៥-២០១៦) ដែលតម្រូវឲ្យលោក Karnavas គោរពតាម៖ "មេធាវីមិនត្រូវបង្ហាញរឿងអាថ៌កំបាំង (Confidence) ឬ ការសម្ងាត់ (Secret) របស់កូនក្តីឡើយ ប្រសិនបើកូនក្តីនោះមិនបានផ្តល់ការយល់ព្រមដោយទទួលបានព័ត៌មានគ្រប់គ្រាន់ លើកលែងតែការបង្ហាញព័ត៌មានណាដែលត្រូវបានអនុញ្ញាតដោយតណ្ហាភាពសម្រាប់អនុវត្តការតំណាងក្តី និង ការបង្ហាញព័ត៌មានដែលអនុញ្ញាតដោយកថាខណ្ឌ (ខ) ខាងក្រោម ឬ វិធាន ៣.៣។ សម្រាប់គោលបំណងនៃវិធាននេះ "រឿងអាថ៌កំបាំង" សំដៅលើព័ត៌មានដែលត្រូវបានការពារដោយបុព្វសិទ្ធិមេធាវី និង កូនក្តីតាមច្បាប់ជាធរមាន ចំណែកឯ "ការសម្ងាត់" សំដៅលើព័ត៌មានផ្សេងទៀតដែលទទួលបានក្នុងទំនាក់ទំនងវិជ្ជាជីវៈ ប្រសិនបើកូនក្តីនោះបានស្នើឲ្យរក្សាជាការសម្ងាត់ ឬ ប្រសិនបើអាចមើលឃើញជាមុនដោយសមហេតុផលថា ការបង្ហាញព័ត៌មាននោះនឹងបង្កការអាម៉ាស់ ឬ បង្កគ្រោះថ្នាក់ដល់កូនក្តី។ ក្នុងការកំណត់ថាតើព័ត៌មានដែលទាក់ទងនឹងការធ្វើជាតំណាងឲ្យកូនក្តីទទួលបានការការពារពីការបង្ហាញព័ត៌មានតាមវិធាននេះ ឬយ៉ាងណានោះ មេធាវីត្រូវដោះស្រាយនូវរាល់ភាពមិនប្រាកដប្រជាអំពីថាតើព័ត៌មានបែបនេះអាចត្រូវបានបង្ហាញ ធៀបនឹងការបង្ហាញព័ត៌មាននោះ"។

[14] បទបញ្ជារដ្ឋបាល ១០.៥ របស់អង្គភាពគាំពារការការពារក្តី៖ "សហមេធាវីការពារក្តីមានកាតព្វកិច្ចធានាថា សមាជិកនៃក្រុមមេធាវីការពារក្តីរបស់ខ្លួនប្រតិបត្តិតាមបទដ្ឋាន និង ភារកិច្ចដាក់ដោយសហមេធាវី"។ *ដូចខាងលើ* បទបញ្ជារដ្ឋបាល ១៧.១៖ "គ្រប់ពេលវេលាទាំងអស់ សហមេធាវី និង សមាជិកដទៃទៀតនៃក្រុមមេធាវីការពារក្តី ត្រូវរក្សាបូរណភាពឯកសារទាំងអស់ រួមទាំងភស្តុតាងដែលត្រូវដាក់ជូនទៅតុលាការ ទោះបីជាលាយលក្ខណ៍អក្សរ ឬ ដោយទម្រង់ណាក៏ដោយ"។ *ដូចខាងលើ* បទបញ្ជារដ្ឋបាល ១៨.៩៖ "រាល់សេចក្តីយោងចំពោះភារកិច្ច ឬ កាតព្វកិច្ចដែលសហមេធាវីអនុវត្តទៅលើសមាជិកនៃក្រុមការពារក្តី"។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krajišnik* សំណុំរឿងលេខ IT-00-39-A សាលដីកាសម្រេចលើសំណើរបស់ Krajišnik និង ញត្តិរបស់អយ្យការ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៧ កថាខណ្ឌ ៣៣-៣៤ ទាក់ទងនឹងបុគ្គលដែលអាចទទួលបានបុព្វសិទ្ធិ។

[15] មាត្រា ៨(១) នៃក្រមសីលធម៌វិជ្ជាជីវៈមេធាវី (ឆ្នាំ ២០១១)៖ "មេធាវីត្រូវគោរព និង ប្រតិបត្តិយ៉ាងសកម្មដោយយកចិត្តទុកដាក់បំផុតដើម្បីធានាឲ្យមានការគោរពការសម្ងាត់វិជ្ជាជីវៈ និង ព័ត៌មានសម្ងាត់អនុលោមតាមលក្ខន្តិកៈ វិធានស្តីពីនីតិវិធី និង ភស្តុតាង និង បញ្ញត្តិរបស់តុលាការ"។ មាត្រា ៣២(២) តម្រូវឲ្យមេធាវីណែនាំជំនួយការ និង បុគ្គលិករបស់ខ្លួនអំពីបទដ្ឋានដែលមានចែង

សមាជិកទាំងអស់នៃក្រុមមេធាវីការពារក្តីគោរពតាមករណីយកិច្ចរក្សាការសម្ងាត់។ ដូចដែលអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon[17] និង សហព្រះរាជអាជ្ញាអន្តរជាតិ[18] បានទទួលស្គាល់ ករណីយកិច្ចរបស់សហមេធាវីចំពោះកូនក្តីរបស់ខ្លួននៅតែបន្ត សូម្បីតែបន្ទាប់ពីទំនាក់ទំនង

---

ក្នុងក្រមសីលធម៌វិជ្ជាជីវៈនេះ។ មាត្រា ៧(៤) តម្រូវឲ្យមេធាវី "ត្រួតពិនិត្យការងាររបស់ជំនួយការ និង បុគ្គលិកផ្សេងទៀតរបស់ខ្លួន រួមទាំង អ្នកស៊ើបអង្កេត ក្រឡាបញ្ជី និង អ្នកស្រាវជ្រាវ ដើម្បីធានាថា ពួកគេអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈនេះ"។

[16] មាត្រា ១៣(ក) នៃក្រមសីលធម៌វិជ្ជាជីវៈនៅចំពោះមុខសាលាជម្រះក្តីអន្តរជាតិ (IT/125 ការកែសម្រួលលើកទី ៣) ("ក្រមសាលាក្តី ICTY")៖ "មិនថាមេធាវីបន្តធ្វើជាតំណាងឲ្យកូនក្តី ឬយ៉ាងណានោះទេ មេធាវីត្រូវរក្សាការសម្ងាត់របស់កូនក្តី និង មិនត្រូវបង្ហាញការសម្ងាត់នោះទៅអ្នកដទៃទៀត ក្រៅពីសមាជិកក្រុមរបស់ខ្លួនដែលត្រូវការព័ត៌មាននោះ សម្រាប់ការបំពេញករណីយកិច្ចរបស់ខ្លួន ពោលគឺព័ត៌មានដែលត្រូវបានប្រគល់ភារៈដល់មេធាវីជាសម្ងាត់ ឬ ក៏ប្រើប្រាស់ព័ត៌មាននោះធ្វើឲ្យអន្តរាយដល់កូនក្តីរបស់ខ្លួន ឬ ជាប្រយោជន៍ដល់មេធាវីខ្លួនឯង ឬ កូនក្តីផ្សេងទៀតឡើយ"។ *ដូចខាងលើ* មាត្រា ៣៤(ក)៖ "មេធាវីដែលមានអំណាចត្រួតពិនិត្យដោយផ្ទាល់លើសមាជិកផ្សេងទៀតក្នុងក្រុមរបស់ខ្លួនត្រូវខិតខំធានាថា ការប្រព្រឹត្តរបស់សមាជិកទាំងនោះស្របតាមកាតព្វកិច្ចវិជ្ជាជីវៈរបស់មេធាវី"។ *សូមមើលផងដែរ* មាត្រា ៨(១), (៣) នៃក្រមសីលធម៌វិជ្ជាជីវៈមេធាវីការពារក្តីរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៨) ("ក្រមសាលាក្តី ICTR)។

[17] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានគូសបញ្ជាក់ថា៖ "ទោះបីជាក្រោយមរណភាពរបស់ អៀង សារី ក៏ដោយ ក៏សហមេធាវីដែលត្រូវបានចាត់តាំង នៅមានករណីយកិច្ចរក្សាភាពស្មោះត្រង់ជាមួយគាត់ រួមមានការការពារសេចក្តីថ្លៃថ្នូរ និងកេរ្តិ៍ឈ្មោះរបស់គាត់"។ *រឿងក្តី មាស មុត* សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបដិសេធការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៤ ឯកសារ D56/18 កថាខណ្ឌ ១៤២។ ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានបដិសេធមិនតែងតាំងសហមេធាវីឲ្យធ្វើជាតំណាងក្តីឲ្យលោក មាស មុត ក៏ដោយ ក៏ដីកាសម្រេចនេះត្រូវបានច្រានចោលដោយអង្គបុរេជំនុំជម្រះ។ *រឿងក្តី មាស មុត* សំណុំរឿងលេខ ០០៣-០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស (អបជ ១១) ផ្សព្វផ្សាយជាសាធារណៈ (សំណៅកោសលុប) សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបដិសេធការតែងតាំងលោក អាង ឧត្តម និង លោក Michael Karnavas មិនឲ្យធ្វើជាសហមេធាវីរបស់គាត់ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៤ ឯកសារ D56/19/38។

[18] នៅក្នុងសេចក្តីសន្និដ្ឋានបន្ថែម ដែលលើកទឡ្ហីករណ៍ពីទំនាស់ផលប្រយោជន៍ក្នុងការតែងតាំងសហមេធាវីឲ្យធ្វើជាតំណាងក្តីឲ្យលោក មាស មុត សហព្រះរាជអាជ្ញាអន្តរជាតិបានលើកទឡ្ហីករណ៍ថា មេធាវីការពារក្តីនៅចំពោះមុខ អ.វ.ត.ក. មាន "កាតព្វកិច្ចក្នុងនាមជាអ្នកកាន់មុខតំណែងជាទីទុកចិត្តក្នុងកម្រិតខ្ពស់បំផុត" ចំពោះកូនក្តីរបស់ខ្លួន និង ថាកាតព្វកិច្ចរក្សាការសម្ងាត់ និង ភាពស្មោះត្រង់នេះ គឺបន្តរហូតដល់ក្រោយពេលដែលកូនក្តីទទួលមរណភាព។ *រឿងក្តី មាស មុត* សំណុំរឿងលេខ ០០៣-០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីទំនាស់ផលប្រយោជន៍របស់សហមេធាវីចាត់តាំង ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០១៣ ឯកសារ D56/7 កថាខណ្ឌ ៧-១៨។

រវាងមេធាវី និង កូនក្តីត្រូវបានបញ្ចប់[19]។ សហមេធាវីមានកាតព្វកិច្ចបង្ហាញអង្គជំនុំជម្រះសាលាដំបូងពីក្តីកង្វល់របស់ខ្លួន អំពីសក្ខីកម្មរបស់លោក Vickery។ លោក Vickery គឺជាអតីតសមាជិកនៃក្រុមមេធាវីការពារក្តី អៀង សារី និង ក្រុមមេធាវីការពារក្តី មាស មុត ហើយគាត់ទំនងនឹងក្លាយជាសមាជិកនៃក្រុមមេធាវីការពារក្តី មាស មុត នាពេលអនាគតទៀតផង។ គាត់មានករណីយកិច្ចរក្សាការសម្ងាត់នូវរាល់ព័ត៌មាន *ទាំងអស់* ដែលគាត់បានដឹង និង ទទួលបាននៅពេលបំពេញកិច្ចការក្នុងក្រុមមេធាវីការពារក្តីទាំងនេះ។

## ក. ការសម្ងាត់ត្រូវតែគោរព ក្នុងរឿងក្តីរបស់លោក អៀង សារី និង លោក មាស មុត

១៣. ទោះបីជាលោក អៀង សារី លែងជាជនជាប់ចោទក្នុងរឿងក្តី ០០២ ក៏ដោយ ក៏សហមេធាវី និង អតីតសមាជិកក្រុមមេធាវីការពារក្តី រួមទាំងទីប្រឹក្សាជំនាញផងដែរ មានកាតព្វកិច្ចការពារការសម្ងាត់នៃរឿងក្តីរបស់លោក អៀង សារី។ សហមេធាវី និង សមាជិកទាំងអស់នៃក្រុមមេធាវីការពារក្តី ក៏មានកាតព្វកិច្ចធានាផងដែរថា ការសម្ងាត់ត្រូវបានគោរពក្នុងរឿងក្តី ០០៣។ ក្នុងនាមជាជនត្រូវចោទក្នុងរឿងក្តី ០០៣ ដែលកំពុងស្ថិតក្រោមការស៊ើបអង្កេតរបស់តុលាការ[20] និង មិនទាន់មានដីកាដំណោះស្រាយ លោក មាស មុត មានផលប្រយោជន៍ស្របច្បាប់ក្នុងការរក្សារឿងក្តីរបស់គាត់ និង ការងាររបស់ក្រុមមេធាវីការពារក្តីរបស់គាត់ជាការសម្ងាត់។

១៤. លោក Vickery បានចំណាយពេលប្រមាណ ១៦៤០ ម៉ោង ធ្វើជាទីប្រឹក្សាជំនាញក្នុងរឿងក្តី ០០២ ឲ្យមេធាវីការពារក្តី អៀង សារី និង ក្នុងរឿងក្តី ០០៣ ឲ្យមេធាវីការពារក្តី មាស មុត។ ក្នុងរឿងក្តី ០០២ គាត់បានជួបជាមួយលោក អៀង សារី ក្រុមគ្រួសាររបស់លោក អៀង សារី និង សហមេធាវីជាច្រើនដង ដើម្បីពិភាក្សាពីការចោទប្រកាន់តាមអង្គហេតុ និង បទចោទប្រកាន់លើលោក អៀង សារី។ កិច្ចពិភាក្សានោះផ្តោតទាំងស្រុងលើរឿងក្តី ០០២ មិនមែនត្រឹមតែផ្នែកដែលត្រូវបានបំបែកនៃរឿងក្តី ០០២/១ ឡើយ។ លោក Vickery មានការសម្ងាត់នៃកិច្ចពិភាក្សា ឧទាហរណ៍ទាក់ទងនឹង

---

[19] *សូមមើល ឧ.ទា.* មាត្រា ១៣(ក) នៃក្រមសាលាក្តី ICTY។ មាត្រា ៨(១) នៃក្រមសាលាក្តី ICTR។ *សូមមើលផងដែរ* សេចក្តីអត្ថាធិប្បាយលើវិធាន ១.៦ នៃក្រមសីលធម៌វិជ្ជាជីវៈអាឡាស្កា (បោះពុម្ពឆ្នាំ ២០១៥-២០១៥)៖ "ករណីយកិច្ចរក្សាការសម្ងាត់នៅបន្តរហូតដល់ក្រោយពេលដែលទំនាក់ទំនងរវាងមេធាវី និង កូនក្តីត្រូវបានបញ្ចប់"។ វិធាន ១.៩(គ) នៃក្រមសីលធម៌វិជ្ជាជីវៈអាឡាស្កា (បោះពុម្ពឆ្នាំ ២០១៥-២០១៦)។

[20] វិធាន ៥៦(១) នៃវិធានផ្ទៃក្នុង៖ "ដើម្បីការពារសិទ្ធិ និង ផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ។ បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួរ ត្រូវរក្សាឲ្យបាននូវការសម្ងាត់"។

ផ្នែកនានានៃដីកាដំណោះស្រាយ ដែលស្តីពីការបោសសម្អាតដែលរងការចោទប្រកាន់ក្នុងបក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក.") ប្រតិបត្តិការផ្ទៃក្នុងរបស់ ប.ក.ក. និង តួនាទីរបស់ជនជាប់ចោទ ការពិនិត្យសាក្សីមួយចំនួន ចម្លើយតបទៅនឹងការចោទប្រកាន់លើលោក អៀង សារី និង យុទ្ធសាស្ត្រការពារក្តី។ ក្នុងរឿងក្តី ០០៣ លោក Vickery បានពិនិត្យស្វែងយល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង អង្គហេតុដែលបានចោទប្រកាន់នៅក្នុងដីកានោះ។ គាត់បានផ្តល់ឱ្យសហមេធាវីនូវការវិភាគពីស្ថានភាពអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង បទចោទប្រកាន់ដែលសំដៅលើលោក មាស មុត។ សហមេធាវីមានចេតនាចង់ជួលគាត់ឱ្យបំពេញការងារទៀត ប្រសិនបើមានការចេញដីកាដំណោះស្រាយ ហើយសំណុំរឿងក្តី ០០៣ ត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងនោះ។

១៥. ការរួមចំណែករបស់លោក Vickery និង ការចូលរួមរបស់គាត់ក្នុងក្រុមមេធាវីការពារក្តី អៀង សារី និង ក្រុមមេធាវីការពារក្តី មាស មុត ស្ថិតក្នុងវិសាលភាពនៃវិធានស្តីពីការរក្សាការសម្ងាត់នៃការប្រាស្រ័យទាក់ទងរវាងមេធាវី និង កូនក្តី។ គាត់គឺជាសមាជិកមួយរូបនៃក្រុមមេធាវីការពារក្តីទាំងពីរក្រុម ហើយគាត់បានប្រាស្រ័យទាក់ទង និង បានពិគ្រោះយោបល់ជាមួយសមាជិកក្រុមមេធាវីការពារក្តី និង ដោយផ្ទាល់ជាមួយលោក អៀង សារី នៅក្នុងរឿងក្តី ០០២។ គាត់មានកាតព្វកិច្ចរក្សាការសម្ងាត់ដែលមានចែងក្នុងវិធានផ្ទៃក្នុង អ.វ.ត.ក. និង បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី[21]។ អង្គជំនុំជម្រះសាលាដំបូងត្រូវធានាថា ការផ្តល់សក្ខីកម្មរបស់គាត់មិនរំលោភបំពានលើការសម្ងាត់ក្នុងរឿងក្តីរបស់លោក អៀង សារី និង លោក មាស មុត។

**ខ. លោក Vickery មិនត្រូវទទួលបានការអនុញ្ញាតឱ្យផ្តល់សក្ខីកម្មអំពីព័ត៌មានណាមួយដែលគាត់បានដឹងក្នុងអំឡុងពេលបំពេញការងារជាមួយមេធាវីការពារក្តី អៀង សារី ឬ មេធាវីការពារក្តី មាស មុត**

១៦. សហមេធាវីមិនជំទាស់ ឬ ជ្រៀតជ្រែកចូលការផ្តល់សក្ខីកម្មរបស់លោក Vickery ក្នុងនាមជាសាក្សីជំនាញក្នុងរឿងក្តី ០០២/០២ ឡើយ។ ពួកគេមិនបានជំទាស់នឹងអង្គជំនុំជម្រះសាលាដំបូង និងភាគីផ្សេងទៀតក្នុងការចោទសួរលោក Vickery ពីសៀវភៅ និង ឯកសារបោះពុម្ពផ្សាយផ្សេងទៀតរបស់គាត់ ព្រមទាំងប្រភពនៃការបញ្ជាក់អះអាងក្នុងឯកសារទាំងនេះឡើយ។

---

[21] *សូមមើល* កថាខណ្ឌ ១២ *ខាងលើ*។

១៧. លោក Vickery មិនត្រូវទទួលបានការអនុញ្ញាតឲ្យផ្តល់សក្ខីកម្មអំពីព័ត៌មានដែលគាត់បានដឹងតាមរយៈការបំពេញការងាររបស់គាត់ជាមួយមេធាវីការពារក្តី អៀង សារី ឬ មេធាវីការពារក្តី មាស មុត ឡើយ។ គាត់មិនត្រូវផ្តល់សក្ខីកម្ម ឬ មិនត្រូវអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូង ឬ ភាគីផ្សេងទៀតសួរអំពី៖ **ក.** ព័ត៌មានណាមួយដែលគាត់បានដឹងក្នុងពេលពិគ្រោះយោបល់ជាមួយលោក អៀង សារី ឬ មេធាវីការពារក្តី អៀង សារី ឬ ពីកិច្ចការស្រាវជ្រាវឯករាជ្យណាមួយដែលគាត់បានធ្វើទាក់ទងនឹងបញ្ហាណាមួយក្នុងរឿងក្តី ០០២ **ខ.** ព័ត៌មានណាមួយដែលគាត់បានដឹងក្នុងពេលពិគ្រោះយោបល់ជាមួយមេធាវីការពារក្តី មាស មុត ឬ ពីកិច្ចការស្រាវជ្រាវឯករាជ្យណាមួយដែលគាត់បានធ្វើទាក់ទងនឹងបញ្ហាណាមួយក្នុងរឿងក្តី ០០៣ ឬ **គ.** ការងារណាមួយផ្សេងទៀតដែលគាត់ត្រូវបានស្នើឲ្យបំពេញ ឬ បានបំពេញឲ្យមេធាវីការពារក្តី អៀង សារី និង មេធាវីការពារក្តី មាស មុត។

១៨. ជាសាមញ្ញ លោក Vickery មិនត្រូវទទួលបានការអនុញ្ញាតឲ្យផ្តល់សក្ខីកម្មអំពីព័ត៌មានណាមួយដែលគាត់បានដឹងក្នុងអំឡុងពេលបំពេញការងារជាមួយមេធាវីការពារក្តី អៀង សារី ឬ មេធាវីការពារក្តី មាស មុត ឡើយ។ អនុញ្ញាតឲ្យគាត់ផ្តល់សក្ខីកម្មបែបនេះ នឹងនាំឲ្យមានការរំលោភបំពានលើករណីយកិច្ចរក្សាការសម្ងាត់របស់លោក Vickery ចំពោះលោក អៀង សារី និង លោក មាស មុត។

### គ. សហមេធាវី ត្រូវទទួលបានការអនុញ្ញាតឲ្យមានវត្តមាននៅក្នុងសាលសវនាការ ក្នុងអំឡុងពេលដែលលោក Vickery ផ្តល់សក្ខីកម្ម

១៩. បន្ថែមលើសំណើសុំការអនុញ្ញាតដាក់សារណាជាលាយលក្ខណ៍អក្សរ ទាក់ទងនឹងសក្ខីកម្មរបស់លោក Vickery សហមេធាវីក៏ស្នើសុំការអនុញ្ញាតឲ្យមានវត្តមាននៅក្នុងសាលសវនាការក្នុងអំឡុងពេលដែលលោក Vickery ផ្តល់សក្ខីកម្ម ព្រមទាំងស្នើសុំសិទ្ធិចូលរួមសវនាការផងដែរ។ សហមេធាវីការពារក្តីគ្មានបំណងរារាំង ឬ ជ្រៀតជ្រែកចូលកិច្ចដំណើរការនីតិវិធីជំនុំជម្រះឡើយ។ ពួកគេស្នើសុំសិទ្ធិចូលរួមសវនាការ គ្រាន់តែដើម្បីឲ្យអាចធ្វើអន្តរាគមន៍តាមមធ្យោបាយជំទាស់ប៉ុណ្ណោះ ប្រសិនបើលោក Vickery ត្រូវបានសួរសំណួរ ឬ ចាប់ផ្តើមផ្តល់ព័ត៌មានដែលទាក់ទងនឹងអ្វីៗដែលគាត់បានដឹងអំពីរឿងក្តី ០០២ ឬ ០០៣ ក្នុងខណៈដែលបំពេញការងារជាមួយមេធាវីការពារក្តី អៀង សារី ឬ មេធាវីការពារក្តី មាស មុត។

២០. លោក Vickey មានអាយុ ៨៥ ឆ្នាំ។ បើតាមដែលសហមេធាវីបានដឹង គាត់មិនធ្លាប់ដែលបានផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការឡើយ។ គេមិនអាចរំពឹងថា គាត់នឹងយល់ដឹងអំពីនីតិវិធី និង ការការពារសម្រាប់អ្នកទាំងឡាយណា ដែលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក នោះទេ។ ហើយគេក៏មិនអាចរំពឹងថា គាត់តែងតែដឹងឡើយ នៅពេលដែលសំណួរ ឬ ចម្លើយជាក់លាក់អាចលើកឡើងពីក្តីបារម្ភនៃការសម្ងាត់។ លើសពីនេះទៀត ខណៈដែលអង្គជំនុំជម្រះសាលាដំបូង អាចមានករណីយកិច្ចជារួមតាមកិច្ចព្រមព្រៀង[22] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[23] និង វិធាន ២១ ធានាឲ្យមានកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ សម្រាប់ជនជាប់ចោទដែលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនោះ អង្គជំនុំជម្រះសាលាដំបូងគ្មានករណីយកិច្ចផ្តល់ទំនុកចិត្តដល់លោក អៀង សារី ឬ លោក មាស មុត ដូចទៅនឹងសហមេធាវីឡើយ។ សហព្រះរាជអាជ្ញា និង ភាគីផ្សេងទៀតនៅក្នុងរឿងក្តី ០០២/០២ ក៏គ្មានកាតព្វកិច្ចផ្តល់ទំនុកចិត្តដូចគ្នានេះចំពោះលោក អៀង សារី ឬ លោក មាស មុត ដែរ។ អាស្រ័យហេតុនេះ សហមេធាវី *ត្រូវ* មានវត្តមាននៅក្នុងអំឡុងពេលដែលលោក Vickery ផ្តល់សក្ខីកម្ម ដើម្បីធានាថាគាត់មិនរំលោភបំពាន (បើទោះបីជាអចេតនាក្តី) លើករណីយកិច្ចរបស់គាត់ក្នុងការរក្សាការសម្ងាត់។

២១. ការស្តាប់សក្ខីកម្មរបស់លោក Vickery នៅក្នុងសវនាការអសាធារណៈ ឬ ការបំបែកផ្នែកនានានៃសក្ខីកម្មរបស់គាត់ពីកំណត់ហេតុជំនុំជម្រះក្តី គឺជាមធ្យោបាយមិនគ្រប់គ្រាន់នោះទេ ក្នុងការដោះស្រាយក្តីបារម្ភរបស់សហមេធាវី។ ទាំងអង្គជំនុំជម្រះសាលាដំបូង និង សហព្រះរាជអាជ្ញា ទាំងភាគីផ្សេងទៀតក្នុងរឿងក្តី ០០២ គ្មានសិទ្ធិស្តាប់ព័ត៌មានដែលទទួលបានពីលោក Vickery ក្នុងអំឡុងពេលដែលគាត់បំពេញការងារជាមួយមេធាវីការពារក្តី អៀង សារី ឬ មេធាវីការពារក្តី មាស មុត ឡើយ។ ព័ត៌មានបែបនេះ គឺជាព័ត៌មានសម្ងាត់ ហើយត្រូវទទួលបានការពារតាមវិធាន ២២ និង ៥៦[24]។ ព័ត៌មានបែបនេះមិនត្រូវយកមកបង្ហាញនៅក្នុងរឿងក្តី ០០២/០២ ឡើយ។

---

[22] មាត្រា ១២-១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[23] មាត្រា ៣៣ថ្មី ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[24] ព័ត៌មាននេះក៏ត្រូវបានការពារផងដែរដោយក្រមសីលធម៌វិជ្ជាជីវៈមេធាវីកម្ពុជា និង អាមេរិក ព្រមទាំងបទប្បញ្ញត្តិរដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តីផងដែរ។ *សូមមើល* ជើងទំព័រ ១២-១៤ *ខាងលើ*។

**ឃ. កិច្ចអន្តរាគមន៍ដោយសហមេធាវី នឹងមិនបង្កជាព្យសនកម្មដល់ភាគីណាមួយ ឬ បង្កឲ្យមានការពន្យាពេលណាមួយនៅក្នុងរឿងក្តី ០០២/០២ ឡើយ**

២២. ការធ្វើអន្តរាគមន៍ដោយសហមេធាវីរបស់លោក អៀង សារី និង លោក មាស មុត ទោះជាតាមរយៈសារណាជាលាយលក្ខណ៍អក្សរ ឬ តាមរយៈការធ្វើអន្តរាគមន៍ដោយផ្ទាល់មាត់នៅក្នុងសាលសវនាការក៏ដោយ នឹងមិនបង្កជាព្យសនកម្មដល់ភាគីណាមួយនៅក្នុងរឿងក្តី ០០២ ឡើយ។ សារណានេះ គ្មានបំណងគាំទ្រ ឬ បំពេញបន្ថែមដល់ទឡ្ហីករណ៍ណាមួយដែលធ្វើឡើងដោយភាគីណាមួយនៅក្នុងរឿងក្តី ០០២ ឬ ដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។ គោលបំណងតែមួយគត់នៃការធ្វើអន្តរាគមន៍នេះ គឺដើម្បីការពារប្រយោជន៍របស់លោក អៀង សារី និង លោក មាស មុត ក្នុងការរក្សាការសម្ងាត់ និង បុព្វសិទ្ធិរបស់មេធាវី-កូនក្តី នៅក្នុងរឿងក្តីរៀងៗខ្លួនរបស់ពួកគេ។

២៣. ការធ្វើអន្តរាគមន៍ដោយសហមេធាវីរបស់លោក អៀង សារី និង លោក មាស មុត នឹងមិនបណ្តាលឲ្យមានការពន្យាពេលនៃរឿងក្តី ០០២/០២ ឡើយ។ តាមដែលសហមេធាវីបានដឹង លោក Vickery គ្រោងនឹងផ្តល់សក្ខីកម្មនៅពាក់កណ្តាលទីពីរនៃខែមិថុនា ឆ្នាំ ២០១៦[25]។ ការទទួលបានសារណាជាលាយលក្ខណ៍អក្សររបស់សហមេធាវីនៅមុនពេលលោក Vickery ផ្តល់សក្ខីកម្ម នឹងមិនតម្រូវឲ្យមានការផ្អាកការផ្តល់សក្ខីកម្មរបស់គាត់ ដើម្បីផ្តល់ពេលវេលាដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិភាក្សាសម្រេចលើសំណើសុំការអនុញ្ញាតនោះឡើយ។ ស្រដៀងគ្នានេះដែរ វត្តមានរបស់សហមេធាវីនៅក្នុងសាលសវនាការ នឹងមិនបណ្តាលឲ្យមានការពន្យាពេលណាមួយនោះដែរ ព្រោះថាវត្តមានរបស់សហមេធាវី នឹងត្រូវបានដាក់កម្រិតយ៉ាងតឹងរ៉ឹងក្នុងរយៈពេល (ត្រឹមតែពេលដែលលោក Vickery ផ្តល់សក្ខីកម្មប៉ុណ្ណោះ) និង ក្នុងវិសាលភាព (ត្រឹមតែផ្នែកណាមួយដែលការ

[25] សហមេធាវីការពារក្តីបានដឹងថា លោក Vickery នឹងផ្តល់សក្ខីកម្មបន្ទាប់ពី កាំង ហ្គេកអ៊ាវ បានបញ្ចប់ការផ្តល់សក្ខីកម្មរបស់គាត់។ គេហទំព័ររបស់ អ.វ.ត.ក. បង្ហាញដូចខាងក្រោមទាក់ទងនឹងការកំណត់ពេលវេលានៃការផ្តល់សក្ខីកម្មរបស់ កាំង ហ្គេកអ៊ាវ៖ "អង្គជំនុំជម្រះបានផ្អាកសវនាការរហូតដល់ថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១៦។ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់សាក្សីដែលមានរហ័សនាម 2-TCW-816 សម្រាប់រយៈពេលបីថ្ងៃ។ លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច នឹងត្រូវចោទសួរដោយភាគីទាំងអស់នៅសប្តាហ៍ទីពីរនៃខែមិថុនា។ *សូមមើល* http://eccc.gov.kh/en/articles/announcement-ruling-chamber-postpone-court-hearings-until-june-2nd។ វាទំនងថា ការផ្តល់សក្ខីកម្មរបស់លោក Vickery មិនអាចចាប់ផ្តើមបានទេរហូតទាល់តែដល់សប្តាហ៍ទីបីនៃខែមិថុនា។

ផ្តល់សក្ខីកម្មរបស់លោក Vickery ប៉ះពាល់លើរឿងក្តីរបស់លោក អៀង សារី ឬ លោក មាស មុតប៉ុណ្ណោះ)។

២៤. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង មានក្តីបារម្ភណាមួយអំពីការពន្យាពេលដែលអាចកើតមានក្នុងរឿងក្តី ០០២/០២ ដែលបង្កឡើងដោយសំណើសុំការអនុញ្ញាតនេះ ឬ បំណងប្រាថ្នារបស់ភាគីណាមួយចង់ឱ្យស្តាប់មតិរបស់ខ្លួនលើបញ្ហានេះនោះ អង្គជំនុំជម្រះសាលាដំបូងអាចគ្រាន់តែវិនិច្ឆ័យលើសំណើដែលមាននៅក្នុងសារណានេះ[26]។

**អាស្រ័យហេតុនេះ** សម្រាប់សំអាងហេតុទាំងអស់ដែលបានលើកឡើងខាងលើ សហមេធាវីគោរពស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

ក. **អនុញ្ញាត**ឱ្យសហមេធាវីដាក់សារណាស្តីពីសក្ខីកម្មរបស់សាក្សីជំនាញ Michael Vickery រួមទាំងសំណើសុំមានវត្តមាន និង សំណើសុំសិទ្ធិចូលរួមសវនាការក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់គាត់។ ឬ ជាជម្រើសផ្សេងទៀត

ខ. **អនុញ្ញាត** តាមសំណើដែលបានលើកឡើងនៅទីនេះ និង **បង្គាប់**៖

១. ឱ្យដាក់កម្រិតតឹងតែងលើសក្ខីកម្មរបស់លោក Vickery ឱ្យស្ថិតនៅត្រឹមព័ត៌មានដែលមានក្នុងសៀវភៅ និង ឯកសារបោះពុម្ពផ្សាយផ្សេងទៀតរបស់គាត់។

២. ឱ្យលោក Vickery មិនទទួលបានការអនុញ្ញាតឱ្យផ្តល់សក្ខីកម្មអំពីព័ត៌មានណាមួយ ដែលគាត់បានដឹងក្នុងអំឡុងពេលបំពេញការងារជាមួយមេធាវីការពារក្តី អៀង សារី និង មេធាវីការពារក្តី មាស មុត។ និង

៣. ឱ្យសហមេធាវីទទួលបានការអនុញ្ញាតឱ្យមានវត្តមាននៅក្នុងសាលសវនាការ ក្នុងអំឡុងពេលដែលលោក Vickery ផ្តល់សក្ខីកម្ម និង អាចធ្វើអន្តរាគមន៍ ឬ ជំទាស់បាន ប្រសិនបើការផ្តល់សក្ខីកម្មរបស់លោក Vickery ចាប់ផ្តើមពិភាក្សាពីបញ្ហាសម្ងាត់ណាមួយ ដែលទាក់ទងនឹងរឿងក្តីរបស់លោក អៀង សារី និង លោក មាស មុត។

---

[26] *សូមមើល* កថាខណ្ឌផ្តើម *ខាងលើ*។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២២** ខែ **មិថុនា** ឆ្នាំ **២០១៦**

សហមេធាវីការពារក្តីលោក អៀង សារី

សហមេធាវីការពារក្តីលោក មាស មុត

| | |
|---|---|
| អាង ឧត្តម | Michael G. KARNAVAS |